**NEWS RELEASE**

UNITED NATIONS HUMAN RIGHTS SPECIAL PROCEDURES

SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# កម្ពុជា៖ ក្រុមអ្នកជំនាញ អ.ស.ប មានការភ្ញាក់ផ្អើលដោយការបង្ហាញឈ្មោះ និងការធ្វើឱ្យអាម៉ាស់ដល់ជនរងគ្រោះពីជំងឺកូវីដ-១៩

ទីក្រុងហ្សឺណែវ (១១ ធ្នូ ២០២០) - ក្រុមអ្នកជំនាញសិទ្ធិមនុស្ស អ.ស.ប* បានសម្តែងការភ្ញាក់ផ្អើលចំពោះការសម្រេចដោយអាជ្ញាធរកម្ពុជា ក្នុងការអនុញ្ញាតឱ្យផ្សព្វផ្សាយព័ត៌មានផ្ទាល់ខ្លួនអំពីបុគ្គលទាំងឡាយ ដែលបានធ្វើតេស្តវិជ្ជមានកូវីដ-១៩ ដែលការផ្សព្វផ្សាយនេះមិនចាំបាច់ក្រោមកាលៈទេសៈណាមួយនោះទេ ហើយវាជាការបំពានធ្ងន់ធ្ងរលើសិទ្ធិឯកជន។

នៅថ្ងៃទី០៤ ខែធ្នូ ក្រសួងសុខាភិបាល បានសម្រេចបង្ហាញអត្តសញ្ញាណ និងព័ត៌មានផ្ទាល់ខ្លួនរបស់បុគ្គលមួយចំនួនដែលឆ្លងជំងឺកូវីដ-១៩ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ដែលការសម្រេចនេះត្រូវបានអនុម័តយល់ព្រមពីលោកនាយករដ្ឋមន្ត្រី។ ចាប់តាំងពីពេលនោះមក ក្រសួងសុខាភិបាលបានចុះផ្សាយបញ្ជីឈ្មោះអ្នកដែលធ្វើតេស្តវិជ្ជមានដោយវីរុសនេះនៅលើគេហទំព័របណ្តាញសង្គមរបស់ខ្លួន។ ព័ត៌មានដែលបានផ្សព្វផ្សាយនេះ រួមមានឈ្មោះ អាយុ ភេទ កន្លែងការងារ និងអាសយដ្ឋានស្នាក់នៅ។ ព័ត៌មានផ្ទាល់ខ្លួន ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយដោយប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ និងនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម។

ក្រុមអ្នកជំនាញស្វាគមន៍សេចក្តីប្រកាសរបស់ក្រសួងសុខាភិបាល ចុះថ្ងៃទី១០ ខែធ្នូ ដែលក្នុងនោះ ក្រសួងបានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការគោរពសិទ្ធិឯកជនរបស់បុគ្គល និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ហើយបានកត់សម្គាល់ថា សេចក្តីប្រកាសព័ត៌មានស្តីពីជំងឺកូវីដ-១៩ របស់ក្រសួងព័ត៌មាន ចុះថ្ងៃទី១១ ខែធ្នូ បានដកចេញនូវរូបថតរបស់បុគ្គលមួយចំនួន ដែលបានធ្វើរោគវិនិច្ឆ័យថាវិជ្ជមានកូវីដ-១៩។ ទោះយ៉ាងណាក៏ដោយ ក្រុមអ្នកជំនាញ នៅតែមានការព្រួយបារម្ភថា សេចក្តីប្រកាសព័ត៌មាននេះ នៅតែបន្តរក្សាទិន្នន័យផ្ទាល់ខ្លួនរបស់បុគ្គល។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា "ការបង្ហាញឈ្មោះ និងការធ្វើឱ្យអាម៉ាស់ជាសាធារណៈដល់អ្នកដែលឆ្លងវីរុសនេះ អាចនាំឱ្យមានការរើសអើង និងការម៉ាក់ងាយ។ សកម្មភាពទាំងនេះ គឺជាការរំលោភបំពានដ៏ធ្ងន់ធ្ងរលើសិទ្ធិឯកជន"។ "វាក៏អាចធ្វើឱ្យប្រជាជនមានការរារែកចិត្តក្នុងការធ្វើតេស្តផងដែរ ប្រសិនជាពួកគេមានរោគសញ្ញាជំងឺកូវីដ-១៩ ឬប្រសិនជាពួកគេសង្ស័យថា ខ្លួនមានហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ នេះដោយសារបាននៅជិតក្បែរអ្នកដែលបានធ្វើតេស្តវិជ្ជមានដោយវីរុសនេះ។

"មានការព្រួយបារម្ភយ៉ាងខ្លាំងថា ទិន្នន័យផ្ទាល់ខ្លួន បាននិងកំពុងប្រមូល ព្រមទាំងផ្សព្វផ្សាយដោយគ្មានការយល់ព្រម។ មិនមានបញ្ញត្តិច្បាប់ណាមួយដែលអនុញ្ញាតឱ្យធ្វើការប្រមូល ដំណើរការ និងបោះពុម្ពផ្សាយទិន្នន័យផ្ទាល់ខ្លួនបែបនេះឡើយ។ ច្បាប់ស្តីពីការរក្សាការសំងាត់ និងសិទ្ធិឯកជន តម្រូវឱ្យធានាការពារសមស្រប និងដោះស្រាយតាមផ្លូវច្បាប់ចំពោះបុគ្គលដែលទទួលរងផលប៉ះពាល់ ដើម្បីធានាការប្រើប្រាស់គត់ហ្មត់នូវទិន្នន័យផ្ទាល់ខ្លួន និងទិន្នន័យទាក់ទងនឹងសុខភាព ព្រមជាមួយនឹងការត្រួតពិនិត្យដោយឯករាជ្យ"។

ការរាតត្បាតជាសកលបានដាក់ការធានាការពារទិន្នន័យចំពោះការធ្វើតេស្ត។ ក្រុមអ្នកជំនាញបានកត់សម្គាល់ថា រាល់ព័ត៌មានផ្ទាល់ខ្លួនណាមួយដែលប្រមូលបាន ក្នុងការតាមស្វែងរកអ្នកដែលប៉ះពាល់ដោយជំងឺកូវីដ-១៩ គួរតែបានកំណត់ត្រឹមតែអ្វីដែលចាំបាច់បំផុត និងមានសមាមាត្រ ដើម្បីបញ្ឈប់ការរីករាលដាលនៃជំងឺនេះតែប៉ុណ្ណោះ។

ក្រុមអ្នកជំនាញបានជំរុញឱ្យអាជ្ញាធរធានាថាប្រជាជនកម្ពុជាគ្រប់រូប ជាពិសេស ជនដែលងាយរងគ្រោះបំផុត អាចទទួលបាននូវវិធានការសុខភាពសាធារណៈ រួមទាំងការធ្វើតេស្ត ការណែនាំ ការប្រឹក្សាយោបល់ និងការពិនិត្យព្យាបាល។

ក្រុមអ្នកជំនាញ អ.ស.ប បានសម្តែងកង្វល់ផងដែរ អំពីការរីករាលដាលនៃជំងឺរាតត្បាតនៅក្នុងពន្ធនាគារកម្ពុជា ហើយបានអំពាវនាវឱ្យរដ្ឋាភិបាលអនុវត្តជាបន្ទាន់តាមការសន្យារបស់ខ្លួន ដើម្បីធ្វើតេស្តជនជាប់ឃុំ។ ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា "ដើម្បីទប់ស្កាត់ការរីករាលដាលជាសក្តានុពលណាមួយដែលអាចកើតមាន យើងជំរុញឱ្យរដ្ឋាភិបាលចាត់រាល់វិធានការចាំបាច់ ដើម្បីទប់ស្កាត់ និងផ្តល់អាទិភាពដល់ការធ្វើតេស្តជាកំហិតសម្រាប់ជនជាប់ឃុំ និងអ្នកទោសទាំងអស់"។

កម្ពុជាត្រូវបានរាយការណ៍ថាមានការឆ្លងជំងឺកូវីដ-១៩ ក្នុងសហគមន៍ជាលើកដំបូង នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០២០ បន្ទាប់ពីមន្ត្រីពន្ធនាគារមួយចំនួន រួមទាំងអគ្គនាយនៃអគ្គនាយកដ្ឋានពន្ធនាគារបានធ្វើតេស្តវិជ្ជមានកូវីដ-១៩។ មន្ត្រីទាំងនេះ បានប៉ះពាល់ជាមួយជនជាប់ឃុំ និងអ្នកទោស នៅពេលដែលពួកគេអាចឆ្លងវីរុសនេះរួចទៅហើយ ដោយបង្កើនការភ័យខ្លាចថាអាចមានការឆ្លងវីរុសក្នុងចំណោមអ្នកទោស និងជនជាប់ឃុំ។

**ចប់**

***អ្នកជំនាញ អ.ស.ប ៖*** អ្នកស្រី រ៉ូណា ស្មីត (Rhona Smith) អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា, លោក ត្លាលេង ម៉ូហ្វូកេង (Tlaleng Mofokeng) អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជនគ្រប់រូបក្នុងការទទួលបានកម្រិតជីវភាពរស់នៅខ្ពស់បំផុតផ្នែកសុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្ត, លោក ចូសិប ខាណាតាស៊ី (Joseph Cannataci) អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិឯកជន។

*អ្នករាយការណ៍ពិសេសគឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជា[នីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស](#)។ នីតិវិធីពិសេសគឺជាស្ថាប័នអ្នកជំនាញឯករាជ្យដ៏ធំបំផុតមួយ ក្នុងប្រព័ន្ធសិទ្ធិមនុស្សអង្គការសហប្រជាជាតិ*

*និតិវិធីពិសេសគឺជាឈ្មោះទូទៅនៃយន្តការស្វែងរកការពិត និងឃ្លាំមើលឯករាជ្យរបស់ក្រុមប្រឹក្សានេះ ដែលដោះស្រាយបញ្ហានៅក្នុងប្រទេសជាក់លាក់ ឬបញ្ហាតាមវិស័យនានានៅគ្រប់តំបន់នៃពិភពលោក។ អ្នកជំនាញនីតិវិធីពិសេសធ្វើការឈរលើគោលការណ៍ស្ម័គ្រចិត្ត។ ពួកគេមិនមែនជាបុគ្គលិករបស់អង្គការសហប្រជាជាតិ ហើយមិនទទួលបានប្រាក់បៀវត្សសម្រាប់ការងាររបស់ពួកគេឡើយ។ ពួកគេឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ ហើយបំពេញការងារតាមសមត្ថភាពបុគ្គលរបស់ពួកគេ។*

*សិទ្ធិមនុស្សអង្គការសហប្រជាជាតិ ទំព័រប្រទេស - កម្ពុជា*

*សម្រាប់ព័ត៌មានបន្ថែម និង**សំណូមពររបស់ប្រព័ន្ធផ្សព្វផ្សាយ** សូមទាក់ទង លោក ណាវីដ អាមេដ (Mr Naveed Ahmad) តាមរយៈ អ៊ីម៉ែល Nahmed@ohchr.org*

*សម្រាប់ការសាកសួរព័ត៌មានទាក់ទងនឹងអ្នកជំនាញឯករាជ្យដទៃផ្សេងទៀតរបស់អង្គការសហប្រជាជាតិ សូមទាក់ទងលោក រ៉ូណាតូ ឌឺ សូហ្សា (Renato de Souza) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩២៨ ៩៨៥៥ / ឬ អ៊ីម៉ែល rrosariodesouza@ohchr.org) និងលោក ហ្សេរីមី ឡូរង់ស៍ (Jeremy Laurence) តាមរយៈ អ៊ីម៉ែល (jlaurence@ohchr.org)*

*តាមដានព័ត៌មានទាក់ទងនឹងអ្នកជំនាញសិទ្ធិមនុស្សឯករាជ្យរបស់ អ.ស.ប នៅលើទំព័រធ្វីតធ័រ Twitter@UN_SPExperts*

*តើអ្នកមានកង្វល់អំពីពិភពលោកដែលយើងរស់នៅមែនទេ?*

***ដូច្នេះ អ្នកត្រូវក្រោកឈរឡើងដើម្បីសិទ្ធិនរណាម្នាក់នៅថ្ងៃនេះ។***

*#Standup4humanrights*

*ហើយចូលមើលទំព័រវេបសាយតាមរយៈ http://www.standup4humanrights.org*